FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



បោះពុម្ពលើកទី៣ ឆ្នាំទី១៧ លេខ២ ខែកុម្ភៈ ឆ្នាំ២០១៨

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ពូជស្រូវស្រាល ខា១៥

**ពូជ**ស្រូវ "ខា១៥" ជាពូជស្រូវស្រាលដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាដើមឆ្នាំ២០១៥។ បច្ចុប្បន្ន ពូជស្រូវខា១៥ បាននឹងកំពុងផ្សព្វផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះមានអាយុកាលខ្លី ផ្តល់ទិន្នផលខ្ពស់ គុណភាពអង្ករល្អ ថ្លា វែងស្រលូន និងបាយទន់ឆ្ងាញ់ពិសារទៀតផង។

## លក្ខណៈពិសេសៗរបស់ពូជស្រូវ ខា១៥

**ពូជ**ស្រូវខា១៥ ជាពូជស្រូវស្រាលមិនប្រកាន់រដូវ ពូជនេះអាចចេញផ្កាបានគ្រប់ពេលវេលាដរាបណាលក្ខខណ្ឌដាំដុះអំណោយផល។ អាស្រ័យដោយហេតុផលខាងលើនេះ ទើបពូជស្រូវខា១៥ អាចដាំដុះនៅដើមរដូវវស្សា (ដំណាំទីមួយនៃរដូវ ឬស្រូវដើមរដូវ) ក្នុងរដូវវស្សា (ដំណាំទីពីរនៃរដូវ) ចុងរដូវវស្សា ស្រូវប្រដេញទឹក (ដំណាំចន្លោះរដូវវស្សា និងរដូវប្រាំង) និងលក្ខខណ្ឌប្រាំងស្រោចស្រព។ ពូជស្រូវខា១៥ មានអាយុកាលចាប់ពីថ្ងៃសាបរហូតដល់ថ្ងៃប្រមូលផលគឺពី៩៥-១០៥ថ្ងៃ។ កម្ពស់ដើម១០០ស.ម និងចំនួនដើមបែកផ្តល់ផលពី៨-១០ដើមក្នុងមួយគុម្ព។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី១០៩-១១៨គ្រាប់ និងមានប្រវែងកួរពី២០-២៩ស.ម។ ពូជស្រូវខា១៥ មានសភាពធន់ទ្រាំមធ្យមទៅនឹងមមាចត្នោត និងអាចផ្តល់ផលពី៤ ទៅ ៧,៤តោនក្នុង១ហិកតា។ អង្កររលូនវែង មានប្រវែងគ្រាប់ជាមធ្យម៧,០ មីលីម៉ែត្រ បន្ទារកម្រាស់ជាមធ្យម២,១ មីលីម៉ែត្រ និងមានអាមីឡូស ២១,៦ ភាគរយ។ ពូជស្រូវ**ខា១៥** ធន់មធ្យមទៅនឹងការបំផ្លាញរបស់ពពួកមមាចត្នោត។

## វិធីសាស្ត្រដាំដុះ

**សម្រាប់**ស្រូវសន្ទូង បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី៣០-៤០គីឡូក្រាមក្នុង១ហិកតា ប៉ុន្តែក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ បរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតាគឺពី១៥-២០គីឡូក្រាម។ ដើម្បីឲ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជមួយគីឡូក្រាមលើផ្ទៃដីថ្នាល១០ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គិសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អគួរស្ទូងសំណាបដែលមានអាយុ១៨-២២ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន២-៣ដើម។ សម្រាប់ស្រូវពង្រោះ បរិមាណគ្រាប់ពូជដែលចាំបាច់គឺ ១៥០គីឡូក្រាមក្នុង១ហិកតា។ គួររៀបចំដីឲ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រោះ។ ការភ្ជួររាស់ គួរតែធ្វើឲ្យបាន២-៣សារ ជាការល្អប្រសើរ។ ប្រសិនបើស្រែអាចបញ្ចេញបញ្ចូលទឹកបាន បន្ទាប់ពីស្ទូង ឬព្រោះបាន២០ថ្ងៃ អាចបញ្ចេញទឹកឲ្យអស់ពីក្នុងស្រែ២-៤ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះ គឺដើម្បីធ្វើឲ្យស្រូវកាន់តែបែកគុម្ពល្អ។



## ការប្រើប្រាស់ជី

**ការ**ប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ នឹងមិនបណ្តាលឲ្យមានការថយគុណភាពគ្រាប់ស្រូវឡើយ។ គួរដាក់ជី ២-៣ដង ក្នុងមួយវដ្តជីវិតរបស់ស្រូវដោយៈ

-បាចលើកទី១ៈ ទ្រាប់បាតមុនពេលស្ទូងប្រើជីធម្មជាតិពី ៥តោន (២០ រទេះ) ក្នុង១ហិកតា និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាងទី១។ សម្រាប់ពេលវេលានៃការបាចជីបំប៉នគឺត្រូវធ្វើឡើងនៅរយៈពេល ៤៥ថ្ងៃ ក្រោយពង្រោះ ឬ ៥០ថ្ងៃ ក្រោយសាបសំណាប។



តារាងទី១ៈ កម្រិតជីណែនាំតាមប្រភេទដី

| ក្រុមដី | ស្រូវស្រាលមិនប្រកាន់រដូវ (ស្រូវប្រាំង និងស្រូវវស្សា) | | | |
|---|---|---|---|---|
| | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក/ហាត) | | | បំប៉ន(គ.ក/ហាត) |
| | អ៊ុយរ៉េ ៤៦-០-០ | ដេ អា ប៉េ ១៨-៤៦-០ | ប៉ូតាស្យូម ០-០-៦០ | អ៊ុយរ៉េ ៤៦-០-០ |
| ដីព្រៃខ្មែរ | ២០ | ២៥ | ៥០ | ២៥ |
| ដីប្រទះឡាង | ២៥ | ៥០ | ៥០ | ៥០ |
| ដីបាកាន ឬ អូរូង | ៥០ | ៦០ | ៥០ | ៨០ |
| ដីទួលសំរោង | ៥០ | ៥០ | ០ | ១០០ |
| ដីគោកត្រប់ | ៥០ | ៧៥ | ៥០ | ៧៥ |
| ដីកំពង់សៀម | ៥០ | ០ | ០ | ៥០ |
| ដីកៀនស្វាយ | ៦០ | ០ | ០ | ៦០ |
| ដីក្រគរ | ១០០ | ៥០ | ០ | ១០០ |
| ដីក្បាលពោធិ៍ | ៨៥ | ០ | ០ | ៨៥ |

## ការប្រមូលផល

- ត្រូវប្រមូលផលស្រូវនៅពេលគ្រាប់ទុំល្អ គឺនៅពេលដែលកួរស្រូវមានគ្រាប់ចាប់ពីពាក់កណ្តាលកួរឡើងទៅមានពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្តាលកួរចុះក្រោមមានពណ៌លឿងទុំស្រាល ហើយគ្រាប់ស្កុកវិញមានពណ៌ស្លាបសេកចាស់។



- គេអាចហាលសម្ងួតស្រូវនៅលើកន្ទេល សំណាញ់មុង តង់កៅស៊ូ និងលានស៊ីម៉ង់ត៍ គឺមិនបណ្តាលឲ្យគុណភាពគ្រាប់ស្រូវឬគ្រាប់ស្រូវពូជខុសគ្នាឡើយ។ កម្រាស់គ្រាប់ស្រូវដែលសមស្របសម្រាប់ការហាលសម្ងួតគឺ ២-៣ស.ម ដែលកម្រាស់គ្រាប់ និងសភាពពន្លឺថ្ងៃគឺជាកត្តាចម្បងក្នុងការកំណត់រយៈពេលហាល និងគុណភាពគ្រាប់ស្រូវៈ
    - ថ្ងៃស្រឡះល្អ ហាលតែ១ថ្ងៃប៉ុណ្ណោះ ដោយកន្លះម៉ោងរីម្តង។
    - ថ្ងៃស្រឡះបង្គួរហាលសម្ងួតរយៈពេល២ថ្ងៃ ដោយ១ម៉ោងរីម្តង។
    - ថ្ងៃមិនស្រឡះគេត្រូវហាលរហូតដល់៣ថ្ងៃ ដោយ២ម៉ោងរីម្តង។




- គ្រាប់ពូជត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិកចងឲ្យជិត រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាច់ដោយឡែកពីគ្រាប់ស្រូវចំណីនៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្តុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។
- ផលស្រូវដែលប្រមូលបាន ត្រូវទុកដាក់ក្នុងជង្រុកឲ្យបានល្អដោយការពារកុំឲ្យសត្វកណ្តុរ មាន់ ទាស៊ី និងមិនឲ្យទទឹក។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្សរ: vathany_thun@yahoo.com chanthypol@gmail.com yadanahun@gmail.com